# វាដល់សន្និសីទម្តងទៀតហើយ

ប្រធាន ថូម៉ាស អេស ម៉នសុន

*សូមអរគុណអ្នកសម្រាប់ក្តីជំនឿរបស់អ្នក និងការលះបង់របស់អ្នកចំពោះដំណឹងល្អ សម្រាប់ក្តីស្រឡាញ់ និងការខ្វល់ខ្វាយ ដែលអ្នកបង្ហាញដល់គ្នាទៅវិញទៅមក និងសម្រាប់ការបម្រើ ដែលអ្នកផ្តល់ ។*

បងប្អូនប្រុសស្រីរបស់ខ្ញុំ វាគឺជាការល្អណាស់ដែលយើងបានជួបជុំគ្នាជាថ្មីម្តងទៀត កាលដែលយើងបានចាប់ផ្តើមសន្និសីទទូទៅប្រចាំឆ្នាំលើកទីមួយរយប៉ែតសិបមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ប្រាំមួយខែ ហាក់ដូចជាកន្លងផុតទៅយ៉ាងឆាប់រហ័ស ដោយខ្ញុំមានការរវល់ក្នុងការទទួលខុសត្រូវជាច្រើន ។ ពរជ័យដ៏អស្ចារ្យមួយ អំឡុងពេលនេះគឺការឧទ្ទិសឡើងវិញនូវព្រះវិហារបរិសុទ្ធ ឡៃអ៊ី ហាវៃ ដែលបានទទួលការជួសជុលជិតពីរឆ្នាំ ។ អមជាមួយខ្ញុំគឺប្រធាន និងបងស្រី ហិនរី ប៊ី អាវរិង អែលឌើរ និងបងស្រី ឃ្វីនថិន អិល ឃុក និងអែលឌើរ និងបងស្រី វីល្លាម អរ វ៉កឃើរ ។ អំឡុងពេលល្ងាចមុនពេលការឧទ្ទិសឡើងវិញដែលបានធ្វើឡើងអំឡុងខែ វិច្ឆិកា យើងបានទស្សនាសមាជិកវ័យក្មេងចំនួន 2,000 នាក់ មកពីមណ្ឌលព្រះវិហារបរិសុទ្ធ កាលដែលពួកគេបានមកពាសពេញមជ្ឈមណ្ឌលសកម្មភាពខាណិនក្នុងបរិវេណសាកលវិទ្យាល័យប៊ី.វ៉ាយ.យូ.ហាវៃ ហើយបានសម្តែងសម្រាប់យើង ។ ការសម្តែងរបស់ពួកគេមានចំណងជើងថា« កន្លែងប្រមូលផ្តុំ »ដែលរៀបរាប់យ៉ាងប៉ិនប្រសប់និងមានការឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍សំខាន់ៗក្នុងប្រវត្តិសាសនាចក្រនិងព្រះវិហារបរិសុទ្ធ ។ វាគឺជាល្ងាចមួយដ៏អស្ចារ្យណាស់ !

ថ្ងៃបន្ទាប់ទៀតគឺជាពិធីដ៏ពោរពេញដោយព្រះ វិញ្ញាណ កាលដែលព្រះ -វិហារបរិសុទ្ធត្រូវបានឧទ្ទិសឡើងវិញបីលើកក្នុងថ្ងៃនោះ ។ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានគង់នៅជាមួយយើងយ៉ាងបរិបូរណ៍ ។

យើងបន្តកសាងព្រះវិហារបរិសុទ្ធ ។ នៅព្រឹកនេះ វាគឺជាឯកសិទ្ធិរបស់ខ្ញុំដើម្បីប្រកាសព្រះវិហារបរិសុទ្ធបីបន្ថែមទៀត ដែលនឹងត្រូវបានសាងសង់នៅខែក្រោយក្នុងឆ្នាំនេះក្នុងតំបន់ដូចតទៅនេះ ៖ ហ្វត ខូឡិន កូឡូរ៉ាដូ មីរីឌាន អៃដាហូ និងវីនីផេហ្គ ម៉ានីតូបា កាណាដា ។ វានឹងប្រាកដនឹងក្លាយជាពរជ័យមួយដល់សមាជិករបស់យើងនៅក្នុងតំបន់ទាំងនោះ ។

ជារៀងរាល់ឆ្នាំ មានពិធីបរិសុទ្ធរាប់លានត្រូវបានធ្វើឡើងក្នុងព្រះវិហារបរិសុទ្ធ ។ សូមឲ្យយើងបន្តស្មោះត្រង់នៅក្នុងការធ្វើពិធីបរិសុទ្ធបែបនេះទៀត មិនត្រឹមតែសម្រាប់ខ្លួនយើងនោះទេ ប៉ុន្តែសម្រាប់មនុស្សជាទីស្រឡាញ់របស់យើងដែលបានស្លាប់ទៅហើយ ដែលមិនអាចធ្វើការណ៍នោះដោយខ្លួនពួកគាត់បានផងដែរ ។

សាសនាចក្របន្តផ្តល់ជំនួយមនុស្សធម៌ ក្នុងគ្រាមហន្តរាយ ។ ថ្មីៗបំផុតនេះ ដួងចិត្ត និងជំនួយរបស់យើងគឺនៅជាមួយនឹងប្រជាជនជប៉ុនដែលរងគ្រោះដោយ ការរញ្ជួយដី និងព្យុះស៊ូណាមិដ៏សាហាវ និងបណ្តាលឲ្យកើតមាននូវបញ្ហានុយក្លេអ៊ែរ ។ យើងបានចែកចាយសម្ភារជាង 63 តោន រួមមានទាំង ម្ហូបអាហារ ទឹក ភួយ ពូក សម្ភារៈអនាម័យ ក្រណាត់ និងប្រេងឥន្ធនៈ ។ យុវវ័យវ័យក្មេងរបស់យើងបានស្ម័គ្រចិត្តរកសមាជិកដែលបាត់ខ្លួន ដោយប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ប្រព័ន្ធផ្សព្វផ្សាយខាងសង្គម និងមធ្យោបាយទំនាក់ទំនងទំនើបផ្សេងៗទៀត ។ សមាជិកកំពុងផ្តល់ជំនួយ ដោយប្រើប្រាស់ម៉ូតូ ដែលបានផ្តល់ដោយសាសនាចក្រ ទៅកាន់តំបន់ដែលពិបាកសម្រាប់ឡានចូលដល់ ។ គម្រោងការបម្រើជាច្រើន ដើម្បីដំឡើងឧបករណ៍អនាម័យ និងឧបករណ៍សម្រាប់សម្អាត កំពុងត្រូវបានរៀបចំក្នុងស្តេក និងវួដជាច្រើនក្នុងទីក្រុង តូក្យូណាហ្គូយ៉ា និងអូសាកា ។ រហូតមកដល់ពេលនេះ ការបម្រើជាង 40,000 ម៉ោង ត្រូវបានបរិច្ចាគពីអ្នកស្ម័គ្រចិត្តជាង 4,000 នាក់ ។ ជំនួយរបស់យើងនឹងបន្តក្នុងប្រទេសជប៉ុន និងក្នុងតំបន់ផ្សេងៗទៀតដែលត្រូវការជំនួយ ។

បងប្អូនប្រុសស្រីរបស់ខ្ញុំ ខ្ញុំសូមអរគុណអ្នកសម្រាប់ក្តីជំនឿរបស់អ្នក និងការលះបង់របស់អ្នកចំពោះដំណឹងល្អ សម្រាប់ក្តីស្រឡាញ់ និងការខ្វល់ខ្វាយ ដែលអ្នកបង្ហាញដល់គ្នាទៅវិញទៅមក និងសម្រាប់ការបម្រើ ដែលអ្នកផ្តល់ក្នុងវួដ និងសាខា និងស្តេក និងមណ្ឌលរបស់អ្នក ។ សូមអរគុណផងដែរសម្រាប់ភាពស្មោះត្រង់របស់អ្នកក្នុងការបង់ដង្វាយមួយភាគដប់ និងដង្វាយតមអាហារ និងសម្រាប់ចិត្តសន្តោសរបស់អ្នក ក្នុងការបរិច្ចាគដល់មូលនិធិផ្សេងៗទៀតរបស់សាសនាចក្រ ។

សម្រាប់ចុងបញ្ចប់នៃឆ្នាំ 2010 មានអ្នកផ្សព្វផ្សាយសាសនា 52,225 នាក់ ដែលកំពុងបម្រើក្នុង 340 បេសកកម្ម ទូទាំងពិភពលោក ។ កិច្ចការផ្សព្វផ្សាយសាសនា គឺជាកត្តាដ៏សំខាន់នៃព្រះនគរ ។ ខ្ញុំសូមស្នើថា បើអ្នកអាច នោះអ្នកអាចពិចារណាពីការបរិច្ចាគដល់មូលនិធិអ្នកផ្សាយសាសនាទូទៅរបស់សាសនាចក្រ ។

ឥឡូវនេះ បងប្អូនប្រុសស្រី យើងអន្ទះសាចង់ស្ដាប់សារលិខិតដែលនឹងផ្ដល់ដល់យើងនៅថ្ងៃនេះ និងថ្ងៃស្អែក ។ ពួកអ្នកដែលនឹងនិយាយមកកាន់យើងបានស្វែងរកជំនួយ និងការណែនាំពីស្ថានសួគ៌ កាលដែលពួកគាត់បានរៀបចំសារលិខិតរបស់ពួកគាត់ ។ ខ្ញុំសូមអធិស្ឋាន ដើម្បីឲ្យយើងអាចពោរពេញដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ និងត្រូវបានលើកឡើង និងបំផុតគំនិត ពេលដែលយើងស្ដាប់ និងរៀនពីសារលិខិតទាំងនោះ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។